# គណបក្ស សិទ្ធិមនុស្ស
HUMAN RIGHTS PARTY

បំរើ ការពារ កសាង

## កើតពីប្រជាពលរដ្ឋ របស់ប្រជាពលរដ្ឋ ដើម្បីប្រជាពលរដ្ឋ

*ព្រឹត្តិប័ត្រព័ត៌មានប្រចាំសប្តាហ៍* *ថ្ងៃសុក្រ ទី១៣ ខែកុម្ភៈ ឆ្នាំ២០០៩* *ព្រឹត្តិប័ត្រលេខ០៧២ ឆ្នាំទី២*


| មាតិកាព័ត៌មាន | ទំព័រ |
|---|---|
| - ប្រតិបត្តិការទ្រង់ទ្រាយធំរបស់ក្រុមហ៊ុន 7NG បោសសំអាតប្រជាពលរដ្ឋដីក្រហម | ១ |
| - ប្រជាពលរដ្ឋជាង១០០គ្រួសារត្រូវរងគ្រោះដោយសារអាជ្ញាធរក្រុងភ្នំពេញ | ២ |
| - ព្រៃឈើនៅខេត្តរតនគិរីរងនឹងការកាប់បំផ្លាញយ៉ាងធ្ងន់ធ្ងរ | ៣ |
| - បទវិចារណកថាចូរបន្តស្វែងរកល្បិចខូចដើម្បីបំពេញភ្នំឆ្កៀតចុះ | ៤ |

## ប្រតិបត្តិការទ្រង់ទ្រាយធំរបស់ក្រុមហ៊ុន 7NGបោសសំអាតប្រជាពលរដ្ឋដីក្រហម

នៅព្រឹកថ្ងៃទី២៤ ខែមករា កន្លងមកនេះ ប្រតិបត្តិការទ្រង់ទ្រាយធំរបស់អាជ្ញាធរក្រុងភ្នំពេញ និងក្រុមហ៊ុន 7NG ដែលមានកងកំលាំងប្រដាប់អាវុធប្រមាណ៣០០នាក់ ប្រដាប់ដោយអាវុធគ្រប់ដៃ និងក្រុមកម្មករស៊ីឈ្នួលឱ្យក្រុមហ៊ុននេះ ស្លិតក្នុងឯកសណ្ឋានអាវពណ៌ក្រហម ពណ៌លឿង និងពណ៌ខៀវប្រមាណ៤០០នាក់ប្រដាប់ដោយកាំបិត និងពូថៅផងនោះ បានបើកប្រតិបត្តិការកំទេចលំនៅដ្ឋានរបស់ប្រជាពលរដ្ឋសហគមន៏ដីក្រហម ស្ថិតក្នុងសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ។

គ្រឿងចក្រជាច្រើនគ្រឿង បានឈូសឆាយកំទេចលំនៅដ្ឋានរបស់ប្រជាពលរដ្ឋចំនួន៩១គ្រួសារនៅម៉ោង៤ព្រឹក ហើយកងកំលាំងប្រដាប់អាវុធបានដាក់ពង្រាយកំលាំងការពារបិទផ្លូវ តាំងពីម៉ោង៣ទៀបភ្លឺមកម្ល៉េះ ។

ការបណ្តេញប្រជាពលរដ្ឋចេញពីតំបន់ដីក្រហម ឱ្យទៅរស់នៅឆ្ងាយក្រុងភ្នំពេញ គឺក្នុងខណ្ឌដង្កោ ដែលជាគោលការណ៏របស់សាលាក្រុងភ្នំពេញ ក៏ដូចជាក្រុមហ៊ុន 7NG បានផ្តល់ប្រាក់២០០០០ដុល្លារ សំរាប់ជាផ្នូរដល់គ្រួសារនិមួយៗដែលយល់ចាកចេញពីតំបន់ដីក្រហម ។ ប៉ុន្តែប្រជាពលរដ្ឋទាំងនោះបានថាទឹកប្រាក់២០០០០ដុល្លារនេះ គឺមិនអាចយកទៅទិញផ្ទះនៅបាននោះទេ ហើយទឹកប្រាក់នេះគ្រាន់តែជាតួលេខតែប៉ុណ្ណោះ ដែលសព្វថ្ងៃនេះពួកគាត់មិនទាន់ទទួលបាននៅឡើយទេ ។ ពួកគាត់ក៏បញ្ជាក់ថា បើទឹកប្រាក់នោះបានត្រឹម៣០០០០ដុល្លារក៏ពួកគាត់យល់ព្រមចាកចេញដែរ ។ ស្ត្រីវ័យ៤០ឆ្នាំម្នាក់ឈ្មោះ **ណារិន** ដែលកំពុងអង្គុយមើលគេរុះរើ និងរើសរបស់បែកបាក់នោះបានរៀបរាប់ថា គាត់សោកស្តាយរកអ្វីប្រៀបផ្ទឹមពុំបានទេ នៅពេលផ្ទះសំបែងរបស់គាត់រងការខូចខាតយ៉ាងដំណំ ។ គាត់បានបន្តទៀតថា តំលៃផ្ទះសំបែងដែលគាត់ទទួលបានគឺ ៥០០០០ដុល្លារ ចំណែកអាជ្ញាធរឱ្យ២០០០០ដុល្លារ ប៉ុន្តែ២០០០០ដុល្លារនោះមិនអាចនៅឡើយទេ ។ ប្រជាពលរដ្ឋជាច្រើនបានអះអាងថា មិនទាន់ទទួលបាននូវចំនួនទឹកប្រាក់ទាំងនោះនៅឡើយទេ មិនតែប៉ុណ្ណោះបានកំទេចផ្ទះរបស់ពួកគាត់រួចរាល់ទៅហើយដែរ ។

ប្រតិបត្តិការទ្រង់ទ្រាយធំដែលអាជ្ញាធរក្រុងភ្នំពេញ និងក្រុមហ៊ុន 7NG កំទេចលំនៅដ្ឋានប្រជាពលរដ្ឋនៅសហគមន៏ដីក្រហម ដែលក្នុងនោះប្រជាពលរដ្ឋប្រមាណ៥០នាក់រងរបួសផងដែរ ។លោក **ម៉ាន់ ឈឿន** អភិបាលរងរាជធានីភ្នំពេញបាន

មានប្រសាសន៍ថា បើទោះបីជាបរិយាកាសជុំវិញលោកមានសភាពអាប់អួរ ពោរពេញទៅដោយកំណាត់ឈើ និងផ្ទះសំបែងបែកខ្ទេចខ្ទីក៏ដោយ តែប្រជាពលរដ្ឋពេលទៅដល់ភូមិដំណាក់ត្រយឹង នោះពួកគាត់នឹងទទួលបានផ្ទះសំបែងដែលអាជ្ញាធរបានត្រៀមទុក និងប្រាក់ចំនួន ៧៧ម៉ឺនរៀល ។ ប្រតិបត្តិការរុះរើ យើងគោរពម៉ោងពេល គឺម៉ោង៤ព្រឹក ដោយមិនមានបំពានលើបងប្អូនប្រជាពលរដ្ឋនោះទេ ។ ក្នុងកិច្ចប្រតិបត្តិការនោះ លោកបានទទួលស្គាល់ថា ប្រជាពលរដ្ឋមានការរងរបួសខ្លះៗក៏ពិតមែន តែប្រជាពលរដ្ឋទាំងនោះមានចំនួន១៤៦២គ្រួសារដែលបានព្រមព្រៀងជាមួយ សាលាក្រុងថានឹងរុះរើលំនៅដ្ឋាន ។ ក្នុងនោះប្រជាពលរដ្ឋចំនួន ១៣៧១ គ្រួសារបានទៅយកផ្ទះនៅភូមិដំណាក់ត្រយឹងរួចរាល់ហើយដែរ គឺនៅសល់តែ៩១គ្រួសារតែប៉ុណ្ណោះដែលមិនព្រមចេញ ។ បើទោះបីជាស្ថិតនៅក្នុងស្ថានភាពណាក៏ដោយ ក្រុមហ៊ុន 7NG បានបំពេញភារកិច្ចនេះរួចហើយ គឺក្នុងការសង់ផ្ទះចំនួន១៤៦២ខ្នងជូនពួកគាត់ ហើយផ្តល់កម្មសិទ្ធិជូនពួកគាត់តែម្តង ។

លោក **ហ៊ឹម យ៉ាន** ស្នងការរងក្រុងភ្នំពេញថ្លែងថា អាជ្ញាធរព្យាយាមអប់រំប្រជាពលរដ្ឋជាមុន ប៉ុន្តែពួកគាត់បានប្រើអំពើហិង្សាមកលើប៉ូលីសដោយគប់នឹងដំបង និងដុំថ្មជាដើម ។ លោកថា កងកំលាំងប្រដាប់អាវុធបានដាក់ពង្រាយកំលាំង តាំងពីម៉ោង៥ព្រឹក និងប្រតិបត្តិការនៅម៉ោង៦ និង៣០នាទីព្រឹក ។ ក្នុងនោះមានប្រជាពលរដ្ឋប្រមាណ៥០នាក់រងរបួស ហើយត្រូវរថយន្តសង្គ្រោះនាំទៅកាន់មន្ទីរពេទ្យ ។ លោក **អំ សំអាត** មន្ត្រីស៊ើបអង្កេតនៃអង្គការលីកាដូបានកត់សំគាល់ថា ការអនុវត្តរបស់អាជ្ញាធរក្រុងគឺជាការបំពារបំពានទៅលើសិទ្ធិសេរីភាព និងសិទ្ធិលំនៅដ្ឋានរបស់ប្រជាពលរដ្ឋដែលរាជរដ្ឋាភិបាល និងអាជ្ញាធរក្រុងមិនគួរយកវិធានការបែបនេះ មកអនុវត្តមកលើប្រជាពលរដ្ឋនោះទេ ។ រីឯលោក **ច័ន្ទ សុវេត** មន្ត្រីស៊ើបអង្កេតនៃសមាគមន៍អាដហុកការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជាបានបញ្ជាក់ថា សកម្មភាពនៃការប្រើប្រាស់កំលាំងទៅកំទេច និងបង្ខិតបង្ខំឱ្យប្រជាពលរដ្ឋរុះរើលំនៅដ្ឋានយ៉ាងដូច្នេះ សង្គមស៊ីវិលមិនអាចទទួលយកបានទេ ។ នេះគឺជាការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរណាស់ ព្រោះការប្រើប្រាស់កំលាំងដើម្បីបំផ្លាញទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋ គឺជាអំពើមួយរំលោភច្បាប់ទាំងស្រុង ។

## ប្រជាពលរដ្ឋជាង១០០គ្រួសារត្រូវ រងគ្រោះដោយសារអាជ្ញាធរក្រុងភ្នំពេញ

ប្រជាពលរដ្ឋសហគមន៍ដីក្រហមជាង១០០គ្រួសារ ដែលអាជ្ញាធរក្រុងភ្នំពេញ និងក្រុមហ៊ុន 7NG បានបណ្តេញចេញ និងកំទេចលំនៅដ្ឋានរបស់ពួកគាត់កាលពីថ្ងៃទី២៤ ខែមករា កន្លងទៅនេះបានថ្លែងប្រាប់ថា ពួកគាត់កំពុងប្រឈមនឹងការខ្វះខាតទឹកស្អាតប្រើប្រាស់ និងគ្មានបង្គន់អនាម័យគ្រប់គ្រាន់ រីឯប្រជាពលរដ្ឋមួយចំនួនទៀតត្រូវបានគេទុកចោល នៅតាមចិញ្ចើមផ្លូវដោយមិនមានផ្ទះសំបែង ។

លោក **ញ៉េប សាធ** ប្រជាពលរដ្ឋសហគមន៍ដីក្រហមបានថ្លែងថា គ្រួសារគាត់បានទទួលផ្ទះពិតមែន ប៉ុន្តែនៅទីនោះមិនមានទឹកប្រើប្រាស់ និងបង្គន់អនាម័យត្រឹមត្រូវនោះទេ ។ ពួកគាត់រស់នៅក្នុងភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ ក្រុងភ្នំពេញ ប្រឈមនឹងការលំបាកសព្វបែប តួយ៉ាងការធ្វើដំណើរទៅធ្វើការ សាលារៀននៅឆ្ងាយពីផ្ទះ ហើយការហូបចុកមិនទាន់ទទួលបាននៅឡើយទេ ។ លោកបន្តទៀតថា លោកមិនមែនប្រឆាំងទៅនឹងការអភិវឌ្ឍន៍របស់សាលាក្រុងទេ ប៉ុន្តែការឈូសឆាយរុះរើលំនៅដ្ឋាននោះគួរតែជូនដំណឹងជាមុន ដូច្នេះទើបអាចធ្វើឱ្យគ្រួសាររបស់ពួកគាត់ និងគ្រួសារដទៃអាចត្រៀមរើផ្ទះសំបែង ដែលមិនបង្កឱ្យបាត់បង់នៅទ្រព្យសម្បត្តិយ៉ាងច្រើនបែបនេះទេ ។ រីឯលោក **ម៉ៅ វុទ្ធី** ជនរងគ្រោះបាត់បង់លំនៅដ្ឋានដែរនោះ បានបញ្ជាក់ថា ចំពោះបងប្អូនដែលទទួលបានផ្ទះនោះ ដោយសារប័ណ្ណគ្រួសារត្រឹមត្រូវដោយឡែកអ្នកមិនមានប័ណ្ណគ្រួសារ ឬក៏ជួលផ្ទះគេនៅ គឺមិនទទួលបានផ្ទះពីក្រុមហ៊ុននោះទេ ។

លោក **អំ សំអាត** មន្ត្រីស៊ើបអង្កេតនៃសមាគមលីកាដូបានតាមដាន នឹងឃ្លាំមើលប្រជាពលរដ្ឋសហគមន៍ដីក្រហមយ៉ាងយកចិត្តទុកដាក់បានថ្លែងថា ក្នុងចំណោមប្រជាពលរដ្ឋជាង១០០គ្រួសារ ដែលបានជន្លៀស ចេញពីតំបន់ដីក្រហមទៅរស់នៅភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅនោះ គិតមកដល់ពេលនេះមាន២០-៣០

គ្រួសារ ក្នុងចំណោម៩១គ្រួសារ ដែលយល់ព្រមទទួលយកផ្ទះ ។ ហើយក្នុងនោះទៀតសោតមានបងប្អូន២-៣គ្រួសារប៉ុណ្ណោះ ដែលយល់ព្រមរស់នៅ រីឯមួយចំនួនទៀតរើចេញដោយសារបញ្ហារស់នៅរបស់ពួកគាត់ជួបប្រទះនូវបញ្ហាទឹក ភ្លើង បង្គន់ មន្ទីរពេទ្យ និងសាលារៀនជាដើម ។ រីឯគ្រួសារខ្លះទៀតសុំគោលការណ៍ជាថវិកាវិញ ដើម្បីរកទិញផ្ទះណាដែលមានតំលៃសមរម្យ សំរាប់ឱ្យកូនរបស់គាត់អាចបន្តការសិក្សា និងមុខរបរលក់ដូររបស់គាត់ ។ លោកបានបន្តទៀតថា អ្នកដែលរស់នៅភូមិដំណាក់ត្រយឹងនោះក៏បានត្អូញត្អែរអំពីបញ្ហាទឹកភ្លើង បញ្ហាសាលារៀន និងមុខរបររកស៊ីរបស់ពួកគាត់។ ចំណែកប្រជាពលរដ្ឋដែលមិនមាន ឈ្មោះក្នុងបញ្ជី៩១គ្រួសារក៏ពួកគាត់ត្រូវបានអាជ្ញាធរ យកទៅចាក់ចោលនៅតាមផ្លូវភូមិដំណាក់ត្រយឹងដែរ ។

សូមរំឭកថា លំនៅដ្ឋានដែលរស់នៅលើដីក្រហមជាង ១០០គ្រួសារត្រូវបានអាជ្ញាធរក្រុងភ្នំពេញ និងក្រុមហ៊ុន 7NG ធ្វើការរុះរើ និងឈូសឆាយលំនៅដ្ឋានរបស់ប្រជាពលរដ្ឋតាំងពីម៉ោង៥ព្រឹក ថ្ងៃទី២៤ ខែមករា ដោយកងកំលាំងប្រដាប់អាវុធប្រមាណជិត៤០០នាក់ បានដាក់ពង្រាយតាំងពីម៉ោង៣ទៀបភ្លឺ សំរាប់ធ្វើការកំទេចលំនៅដ្ឋានរបស់ប្រជាពលរដ្ឋ ដែលនៅក្នុងដៃបុគ្គលិកនីមួយៗរបស់ក្រុមហ៊ុន 7NG ប្រដាប់ដោយកំបិត ពូថៅ និងគ្រឿងយន្តសំរាប់ធ្វើការឈូសឆាយ ។

កិច្ចសហប្រតិបត្តិការរបស់អាជ្ញាធរក្រុងភ្នំពេញ និងក្រុមហ៊ុន 7NG នេះត្រូវបានអ្នកនយោបាយ និងសង្គមស៊ីវិលមើលឃើញថាទទួលបានជោគជ័យទាំងស្រុងស្ថិតក្រោមតំណក់ទឹកភ្នែក និងក្តីឈឺចាប់របស់ប្រជាពលរដ្ឋស្លូតត្រង់ ។

## ព្រៃឈើនៅខេត្តរតនគីរីរងនឹងការកាប់បំផ្លាញយ៉ាងធ្ងន់ធ្ងរ

ការកាប់បំផ្លាញព្រៃឈើកំពុងកើតមាននៅឃុំសេដា ស្រុកលំផាត់ ព្រមទាំងរំលោភបំពានយកដីចំការវិលជុំរបស់សហគមន៍ជនជាតិទំពួននៅឃុំលុងឃុង ស្រុកបរកែវនៅតែកើតមានពីសំណាក់ក្រុមហ៊ុនមួយចំនួននៅខេត្តរតនគីរី ។

តំណាងសហគមន៍ជនជាតិទំពួនបានបញ្ជាក់ថា ឥឡូវនេះការរំលោភបំពានយកដីសហគមន៍ជនជាតិទំពួន នៅក្នុងឃុំលុងឃុង ស្រុកបរកែវ នៅតែបន្តកើតមានដោយសារក្រុមហ៊ុនក្នុងស្រុកមួយចំនួនបានរំលោភយកដីសហគមន៍ជនជាតិទំពួន ដែលដីនោះត្រូវនៅក្នុងប្លង់ដីចំការកៅស៊ូក្រុមហ៊ុន ដែលដីទាំងនោះត្រូវបានជនខិលខូចលួចយកទៅលក់ហើយបង្កជាបញ្ហារហូតមកដល់សព្វថ្ងៃនេះ ។

ការឈូសឆាយដីរាប់រយហិកតា ត្រូវទទួលការខុសត្រូវដោយក្រុមហ៊ុនមួយ ប៉ុន្តែការឈូសឆាយដីដាំកៅស៊ូបាន៧០ហិកតា ក្នុងនោះមានការបណ្តេញប្រជាពលរដ្ឋជនជាតិដើមភាគតិចផងដែរ ។ ប៉ុន្តែប្រជាពលរដ្ឋនៅទីនោះបដិសេធមិនព្រមចេញ ពីព្រោះពួកគាត់រស់នៅទីនោះតាំងពីយូរយាណាស់មកហើយ ហើយបើពួកគាត់រើចេញ តើឱ្យពួកគាត់ទៅរស់នៅឯណា ? ទាក់ទងនឹងបញ្ហាខាងលើនេះយើងមិនអាចសុំការបំភ្លឺពីលោក **មួង ប៉យ** អភិបាលខេត្តរតនគីរី និងលោក **វិមាន** ប្រធានរដ្ឋបាលព្រៃឈើនៅខេត្តរតនគីរីបានទេដោយសារគ្មានអ្នកទទួល ។ ប៉ុន្តែលោក **ឡេង យុ** មន្ត្រីគ្រប់គ្រងរដ្ឋបាលព្រៃឈើនៅស្រុកលំផាត់ បានឱ្យដឹងជុំវិញពីការកាប់បំផ្លាញព្រៃឈើនោះគឺលោកបានធ្វើរបាយការណ៍ និងបំពេញសំណុំបែបបទជូនទៅថ្នាក់លើអស់ហើយ ហើយនេះក៏ជាសមត្ថកិច្ចរបស់ថ្នាក់លើ ។

លោក **ប៉ែន ប៊ុណ្ណា** អ្នកសំរបសំរួលនៃសមាគមអាដហុកនៅខេត្តរតនគីរីបានបញ្ជាក់ថា អ្នកដែលបន្តការកាប់បំផ្លាញព្រៃឈើនៅខេត្តរតនគីរីគឺសុទ្ធតែជាអ្នកមានអំណាច ហើយអ្នកខ្លះទៀតក៏បានទទួលលុយពីគេរួចហើយដែរ ។ សព្វថ្ងៃនេះមានសំណុំរឿងយ៉ាងច្រើនដែលសមាគមន៍អាដហុកទទួលបាន និងបញ្ជូនបន្តទៅតុលាការ ហើយក៏សង្ឃឹមថា បើទោះជាជនដែលប្រព្រឹត្តបទល្មើសទាំងនោះកាប់បំផ្លាញព្រៃឈើយកទៅធ្វើអ្វីក៏ដោយ ក៏តុលាការធ្វើការផ្តន្ទាទោសទៅតាមច្បាប់ផងដែរ ។ លោកក៏បានសង្កត់ធ្ងន់ថា នៅតំបន់ណាដែលមានដីក្រហម គឺទីនោះមានការកាប់រានព្រៃឈើទាំងអស់ ម្យ៉ាងទៀតព្រៃឈើដែលរីកដុះដាលនៅតំបន់ដីក្រហមរាប់ម៉ឺនហិកតាស្ទើរតែវិនាសបាត់បង់ទៅហើយ ហើយឥឡូវនេះនៅតែបន្តធ្វើការកាប់បំផ្លាញជារៀងរាល់ថ្ងៃ ដែលក្នុងនោះសុទ្ធតែជាឈើប្រណិតៗ និងមានអាយុរាប់រយឆ្នាំទៀតផង ។

## បទវិចារណកថាៈ ចូរបន្តស្វែងរកល្បិចខ្វះចដើម្បីបំពេញក្អមទៀតចុះ

រៀងរាល់ពេលព្រឹក ព្រលឹម និងពេលល្ងាច យើងបានឮសំឡេងមនុស្សពីរនាក់ឆ្លើយឆ្លងបន្ទរដាក់គ្នា តាមរលកធាតុអាកាស ដូចជាអ្នកចំរៀងអាយ៉ៃគ្មានភ្លេងកំដរ ។ ជនទាំងពីរនេះម្នាក់ជាអ្នកសួរ និងម្នាក់ជាអ្នកឆ្លើយ ។ សំនួរចំលើយង៉ូវៗដដែលៗនេះ គឺគេនិយាយពីសម្ព័ន្ធភាពរវាងគណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្ស ជាពិសេស គឺគេលើកសំនួរឆ្លើយឆ្លងគ្នានិយាយរិះគន់បង្កាច់បង្ខូចតែគណបក្សសិទ្ធិមនុស្សប៉ុណ្ណោះ ។ ប៉ុន្តែគណបក្សដ៏ទៃៗទៀត គេមិនហ៊ាននិយាយជាពិសេស គឺគណបក្សកាន់អំណាចតែម្តង ។ សំដីដែលហូរចេញពីមាត់របស់គេ គឺគណបក្សសិទ្ធិមនុស្សជាក្រុមជ្រុលនិយមជាក្រុមមនុស្សកន្លះក្អម ។ល។ និង ។ល។ ដោយភ្លេចថាអ្នកណាកន្លះ អ្នកណាពេញក្អម អ្នកណាជ្រុលនិយម ហើយអ្នកណាមិនគិតពីជាតិនោះ ប្រជាពលរដ្ឋវិនិច្ឆ័យច្បាស់ណាស់។ សំណាងដែរ ដែលពួកគេទាំងពីរពួននិយាយក្នុងបន្ទប់ បើសិនជាគេមកនិយាយនៅទីធ្លារសាធារណៈណាមួយ យើងមិនដឹងថាតើសាធារណជន វាយតំលៃពួកគេទាំងពីរបែបណានោះទេ ហើយវាសនារបស់ពួកគេមិនដឹងជាទៅជាយ៉ាងណា ?។ ល្មើយគួរអាណិតមនុស្សទាំងពីរនាក់នោះដែរ ដែលគ្មាននរណានិយាយរកក្រៅតែគ្នាពីរនាក់នោះ យើងសុខចិត្តដាក់ខ្លួននិយាយរកពួកគេបន្តិចចុះ ។

ទោះបីពួកគេប្រមាថយើងថា ជាក្រុមជ្រុលនិយម ក្រុមកន្លះក្អមយ៉ាងណាក៏ដោយ ក៏ពួកស្មើរនិយម និងពួកពេញក្អម មិនអាចរារាំងសម្ព័ន្ធភាព មិនឱ្យចេញជារូបរាងតាមបំណងរបស់ខ្លួនបានដែរ សម្ព័ន្ធភាពរវាងគណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្សនៅពេលនេះបានកើតរួចហើយ និងឈានទៅបង្កើតទៅជា " ចលនានយោបាយប្រជាធិបតេយ្យដើម្បីការផ្លាស់ប្តូរ " នៅកម្ពុជាមួយកំរិតទៀត ។ អ្នកកំពុងតែភ័យស្លន់ស្លោរ និងចលនានយោបាយប្រជាធិបតេយ្យនេះខ្លាំងណាស់ឬ ព្រោះថាចលនាប្រជាធិបតេយ្យដើម្បីការផ្លាស់ប្តូរនេះបាននឹងកំពុងតែទទួលការ អបអរសាទរយ៉ាងច្រើនកុះករពីសំណាក់បងប្អូនជនរួមជាតិខ្មែរទាំងក្នុង និងក្រៅប្រទេស ។ គួរតែលោកបណ្ឌិតពេញក្អម និងអ្នកសួរសំណួរកែប្រែមកអបអរសារដូចប្រជាពលរដ្ឋខ្មែរដែរ ។

ក្រោយពីទប់លេងជាប់ហើយនោះ លោកបណ្ឌិតស្មើរនិយម ឬពេញក្អមបានប្តូរយុទ្ធសាស្ត្រពីទប់ស្កាត់ មកបំបែកបំបាក់ម្តងតាមការបង្គាប់បញ្ជារបស់ម្ចាស់ឆ្នាំងបាយ ថែមទាំងវាយប្រហារទៅលើអង្គាសង្គមស៊ីវិលម្តងវិញ បើមិនធ្វើដូច្នេះ ធ្វើម៉េចនឹងបានចិញ្ចឹមឆ្នាំងតទៅទៀត ។ ពេលនេះហើយ ដែលប្រជាពលរដ្ឋខ្មែរបានស្គាល់ក្រយៅ លោកបណ្ឌិតពេញក្អមដែលមានចេតនាយកជើងមកទឹក ក្នុងបំណងមិនចង់ផ្លាស់ប្តូរសង្គមបច្ចុប្បន្នដែលគ្រប់គ្រងដោយជនផ្តាច់ការ ដូចពាក្យស្លោកមួយឃ្លាពោលថា បើមិនជួយច្ងកជួយចែកកុំយកជើងរាទឹក ។ដូច្នេះសូមលោកបណ្ឌិត ស្មើរនិយម ឬពេញក្អម ! បន្តការងារនិងស្វែងរកយុទ្ធសាស្ត្រចាក់រុកឆ្កឹះឆ្កៀលបំបែកបំបាក់ ចលនានយោបាយប្រជាធិបតេយ្យដើម្បីការផ្លាស់ប្តូរដែលខ្មែរគ្រប់រូបចង់បាននោះទៀតចុះ ។

| គ្រប់គ្រងការផ្សព្វផ្សាយ | | |
|---|---|---|
| លោក | ម៉ី សាន | ទូរស័ព្ទលេខៈ ០១១ ៩០៤ ០៣១ |
| កញ្ញា | គង់ វណ្ណា | ទូរស័ព្ទលេខៈ ០១២ ៨៦៥ ២៥៥ |
| ផ្ទះលេខ៧២-៧៤,ផ្លូវលេខ៥៩៨, សង្កាត់បឹងកក់២,ខណ្ឌទួលគោក,ក្រុងភ្នំពេញ | | |

**ការអភិវឌ្ឍន៍គឺដើម្បីជាប្រយោជន៍ដល់ប្រជាពលរដ្ឋ !**